# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍សន្តយ៉ូសែប
# ផ្សារតូច ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩
# រកមធ្យោបាយដើម្បីប្រកាសដំណឹងល្អ

**អត្ថបទទី១៖ អម៉ូស ៨,៤-៧**

អស់អ្នកដែលចេះតែជិះជាន់អ្នកក្រីក្រ ហើយធ្វើឲ្យជនទុគ៌តត្រូវវិនាស ចូរស្ដាប់ពាក្យខ្ញុំ។ អម ៨,៤

**អត្ថបទទី២៖ ធីម៉ូថេទី១ ២,១-៨**

ព្រះអង្គបានតែងតាំងខ្ញុំឲ្យប្រកាសសក្ខីភាពនេះ ឲ្យខ្ញុំធ្វើជាគ្រីស្តទូត និងធ្វើជាគ្រូអប់រំសាសន៍ដទៃអំពីជំនឿ និងអំពីសេចក្ដីពិត។ ១ធម ២,៧

**ដំណឹងល្អ៖ លូកា ១៦,១-១៣**

អ្នកណាស្មោះត្រង់ក្នុងកិច្ចការដ៏តូច អ្នកនោះក៏ស្មោះត្រង់ក្នុងកិច្ចការធំដុំដែរ អ្នកណាបោកបញ្ឆោតក្នុងកិច្ចការដ៏តូច អ្នកនោះក៏តែងបោកបញ្ឆោតក្នុងកិច្ចការធំដុំដែរ។ លក ១៦,១០

បងប្អូនជាទីស្រឡាញ់!

ពួកគណៈផារីស៊ី កំពុងរិះគន់ព្រះយេស៊ូព្រោះគេឃើញ ព្រះអង្គអង្គុយញ៉ាំបាយជាមួយអ្នកទារពន្ធ ដែលជាមនុស្សពោរពេញដោយអំពើបាប ជាមនុស្សដែលសង្គមមិនចូលចិត្ត។ ព្រះយេស៊ូចាប់ផ្ដើមមានប្រស្នា ដើម្បីបំភ្លឺគណៈផារីស៊ីដែលពូកែអួតខ្លួន ពូកែបង្ហាញស្នាដៃរបស់គេអស់ពីសមត្ថភាព ជួយអ្នកក្រីក្រ អំពីរបៀបដែលគេអធិដ្ឋាន អំពីរបៀបដែលគេធ្វើនៅមុខមនុស្សទាំងអស់គេខិតខំអស់ពីសមត្ថភាព។ ប៉ុន្តែពេលចូលនៅក្នុងភាពងងឹត និងនៅក្នុងដួងចិត្តរបស់គេយើងឃើញមនុស្សនេះមានមុខពីរ មួយនៅក្នុងពន្លឺដើម្បីឲ្យគេឃើញគេសរសើរ និងមួយទៀតខាងក្នុងគេគិតលើសពីអ្នកទារពន្ធនិងលើសពីអ្នកមានបាប។

ព្រះយេស៊ូចង់បង្ហាញ ឲ្យអ្នកដែលវង្វេងផ្លូវនៅក្នុងជីវិតរកឃើញពន្លឺ ដើម្បីទៅជាមនុស្សថ្មីដើម្បីកែប្រែចិត្តគំនិត។ ប្រសិនបើ នៅក្នុង១០០នាក់យើងបាត់បង់មនុស្សម្នាក់ ហើយម្នាក់នោះបានកែប្រែចិត្តគំនិត ណែនាំឲ្យព្រះជាម្ចាស់ពោរពេញដោយអំណរសប្បាយ។ ថ្ងៃនេះ ព្រះយេស៊ូបន្តបង្ហាញដល់គណៈផារីស៊ី ដល់មនុស្សដែលពូកែតាំងខ្លួនជាមនុស្សល្អ ដូចអ្នកមាននៅពេលគាត់ចូលវិហារគាត់ឲ្យលុយយ៉ាងច្រើនទៅក្នុងដង្វាយ ក៏ប៉ុន្តែគាត់នៅមានលុយច្រើនទៀត ហើយយាយមេម៉ាយម្នាក់ដែលនៅសល់លុយតិចតួចដើម្បីចិញ្ចឹមជីវិតរបស់គាត់ តែគាត់ឲ្យលុយនេះទាំងអស់ដើម្បីចូលដង្វាយ នេះជារបៀបដែលព្រះយេស៊ូចូលចិត្តណាស់។

ព្រះយេស៊ូ ចង់ណែនាំឲ្យយើងគិតថែមទៀតអំពីជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលយកចិត្តទុកដាក់រស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ យើងជាអ្នកដែលបង្ហាញមុខ បង្ហាញខ្លួនដើម្បីបានប័ណ្ណសរសើរ កោតសរសើរពីបងប្អូនឯទៀតៗ ឬយើងយកចិត្តទុកដាក់កែប្រែចិត្តគំនិតនៅខាងក្នុង ដើម្បីមានជីវិតថ្មីដែលភ្ជាប់ជាមួយព្រះជាម្ចាស់។ គម្ពីរនេះ ព្រះយេស៊ូសរសើរមនុស្សម្នាក់ដែលមានរបៀបមិនត្រឹមត្រូវ **"ម្ចាស់កោតសរសើរ អ្នកបម្រើដែលប៉ិនប្រសព្វបោកបញ្ឆោត មនុស្សក្នុងលោកនេះតែងតែប៉ិនប្រសព្វរកស៊ីជាមួយគ្នា ជាងអស់អ្នកដែលស្គាល់ព្រះពន្លឺរបស់ព្រះជាម្ចាស់ទៅទៀត"** ប្លែកព្រះយេស៊ូសរសើរមនុស្សដែលបោកប្រាស់ម្ចាស់។ សម្រាប់យើងដែលស្គាល់ពន្លឺរបស់ព្រះជាម្ចាស់ ព្រះយេស៊ូចង់ឲ្យយើងមានមធ្យោយបាយ មានរបៀបដើម្បីរស់នៅក្នុងលោកីយ៍នេះ កុំឲ្យយើងប្រព្រឹត្តខុសនឹងយុត្តិធម៌ ខុសនឹងច្បាប់។ ព្រះយេស៊ូ មិនកោតសរសើរមនុស្សដែលអត់មានចិត្តស្មោះ ប៉ុន្តែកោតសរសើរមនុស្សដែលមានគំនិតវែងឆ្ងាយដើម្បីប្រកាសដំណឹងល្អ ដើម្បីជួយអ្នកក្រីក្រយ៉ាងពិតប្រាកដ។ មិនមែនជួយអ្នកក្រីក្រនៅក្នុងរបៀបអាក្រក់ ប៉ុន្តែជួយអស់ពីសមត្ថភាពដែលយើងមាន។ សន្ត ម៉ាតាំង ជាសន្តម្នាក់ល្បីគាត់បានឲ្យអាវរបស់គាត់ទៅអ្នកក្រីក្រ គាត់ហែកអាវគាត់ជាពីរឲ្យពាក់កណ្តាលទៅអ្នកក្រីក្រ គាត់ល្បីរហូតដល់សព្វថ្ងៃ ដោយសាររបៀបដែលយើងត្រូវជួយអ្នកតូចតាច។ មូលហេតុដែលគាត់ឲ្យតែពាក់កណ្តាលព្រោះគាត់ជាទាហាន សម័យនោះសម្ភារៈរបស់ទាហានពាក់កណ្តាលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងពាក់កណ្តាលជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ដូច្នេះ នៅពេលគាត់ហែកអាវរបស់គាត់គាត់ឲ្យទ្រព្យសម្បត្តិរបស់គាត់ផ្ទាល់ទៅអ្នកក្រីក្រ។

ជីវិតរបស់យើង **តើយើងធ្វើដូចម្តេចដើម្បីចូលទៅក្នុងការប្រកាសដំណឹងល្អ អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់? តើយើងមានរបៀបអ្វីខ្លះ ដើម្បីប្រកាសដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលកំពុងយាងមកលើផែនដីនេះ និងនៅស្ថានបរមសុខ?** សន្តលូវីស និងសន្តីហ្សេលី បានអប់រំណែនាំកូនគេនៅលើផែនដីនេះ ត្រៀមខ្លួនដើម្បីទទួលទ្រព្យសម្បត្តិនៅស្ថានបរមសុខ ដោយអធិដ្ឋាន ដោយស្រឡាញ់ព្រះជាម្ចាស់ ដោយស្រឡាញ់អ្នកក្រីក្រអស់ពីដួងចិត្ត មិនមែនធ្វើដើម្បីឲ្យគេសរសើរ។ លូវីស និងហ្សេលី ចូលអភិបូជារាល់ព្រឹកម៉ោង៥ ជាអភិបូជាសម្រាប់កម្មករសម្រាប់អ្នកក្រីក្រ សម្រាប់អ្នកតូចតាច សំខាន់មិនមែនដើម្បីបង្ហាញខ្លួន សំខាន់ដើម្បីអធិដ្ឋានជាមួយព្រះជាម្ចាស់ ទទួលព្រះកាយព្រះគ្រីស្ត ដើម្បីទទួលកម្លាំងពីព្រះជាម្ចាស់ថែមទៀត។ រាល់ថ្ងៃចន្ទពេលរសៀល គេបើកទ្វារផ្ទះរបស់គេដើម្បីស្វាគមន៍អ្នកក្រីក្រ អ្នកជំងឺ អ្នកដែលគ្មានទីពឹងអ្នកដែលកំពុងពិបាកចិត្ត អ្នកដែលកំពុងវង្វេងនៅក្នុងជីវិត ដើម្បីមកទទួលសេចក្តីសុខ ទទួលភាពកក់ក្តៅដែលមកពីព្រះជាម្ចាស់ផ្ទាល់តាមរយៈគ្រួសារនេះ។

យើងត្រូវការគិតពិចារណា ទ្រព្យសម្បត្តិដែលយើងបានទទួលពីព្រះជាម្ចាស់ មានព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានជីវិតជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់តាមរយៈអគ្គសញ្ញាជាមួយព្រះគ្រីស្ត និងព្រះយេស៊ូផ្ទាល់។ **តើយើងធ្វើយ៉ាងម៉េចដើម្បីឲ្យទ្រព្យសម្បត្តិនេះ រីកចម្រើននៅលើផែនដីនេះ និងចែករំលែកដល់បងប្អូនឯទៀតៗ?** យើងធ្វើ ដើម្បីណែនាំឲ្យអំណរសប្បាយនៃដំណឹងល្អទៅដល់បងប្អូនឯទៀតៗ។ ឲ្យយើងរៀងៗខ្លួនចេះបើកភ្នែក មើលអ្នកក្រីក្រឲ្យយើងចេះជួយលើកទឹកចិត្ត ធ្វើដំណើរជាមួយគាត់។ ព្រះយេស៊ូ ឲ្យយើងបង្កើតមិត្តភាពយ៉ាងច្រើន ប៉ុន្តែមិនមែនតែជាមួយមិត្តភក្តិដែលជាឯកឧត្តម លោកស្រី អ្នកនាងកញ្ញា លោកជំទាវធំៗ មិត្តភក្តិដែលជាអ្នកក្រីក្របំផុត ដោយសារជាអ្នកក្រីក្រហ្នឹង ដែលនឹងស្វាគមន៍យើងនៅស្ថានបរមសុខ។ លោកឡាសាដែលនៅមុខផ្ទះអ្នកមាន រាល់ថ្ងៃអ្នកមានអត់ដែលមើលឃើញគាត់ ពេលអ្នកមានស្លាប់គាត់ទៅឋាននរក និងឡាសាគាត់នៅជាមួយព្រះជាម្ចាស់។ ពេលយើងយកចិត្តទុកដាក់ជាមួយអ្នកក្រីក្រ យើងដឹងថាយើងយកចិត្តទុកដាក់ជាមួយព្រះយេស៊ូផ្ទាល់ យើងបង្កើតមិត្តភាព យើងមានមិត្តសម្លាញ់ច្រើន ដែលចាំស្វាគមន៍យើងនៅស្ថានបរមសុខ។

យើងចូលនៅក្នុងរដូវបុណ្យភ្ជុំ ជាពេលវេលាដើម្បីនឹកឃើញដល់បងប្អូនឯទៀតៗ ដែលបានទទួលមរណភាពហើយ ដើម្បីអធិដ្ឋានសូមវិញ្ញាណក្ខន្ធបងប្អូនរបស់យើង ទូលអង្វរព្រះជាម្ចាស់ឲ្យទទួលស្វាគមន៍វិញ្ញាណក្ខន្ធបងប្អូនរបស់យើង។ ប៉ុន្តែ ជាពេលវេលាដើម្បីអធិដ្ឋានសម្រាប់យើងដែលនៅលើផែនដីនេះ ឲ្យយកចិត្តទុកដាក់រស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ រកមធ្យោបាយដើម្បីប្រកាសដំណឹងល្អ ដើម្បីរស់នៅជាគ្រីស្តបរិស័ទប្រចាំថ្ងៃជាមួយបងប្អូនឯទៀតៗ ដែលមិនស្គាល់ព្រះយេស៊ូ ដែលមិនដឹងអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ តែដោយសារយើងគេអាចស្គាល់ព្រះយេស៊ូ និងស្គាល់ដំណឹងល្អរបស់ព្រះអង្គ។

យើងអធិដ្ឋាន យើងទូលអង្វរតាមរយៈមរណសាក្សី នៅប្រទេសកម្ពុជា នៅប្រទេសឡាវ នៅប្រទេសកូរ៉េ ជាគំរូដែលបានលះបង់ចោលរហូតទទួលមរណភាពដោយសារជំនឿ ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គេនៅស្ថានបរមសុខហើយ គេកំពុងទន្ទឹងរង់ចាំយើង ប៉ុន្តែឲ្យយើងចាប់ផ្តើមពីពេលនេះតទៅដើម្បីរស់នៅក្នុងសេចក្តីសុខ ដោយចែករំលែកទ្រព្យសម្បត្តិដែលយើងបានទទួលពីព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗ។

រកមធ្យោបាយ ដើម្បីជួយ ដើម្បីភ្ជាប់ជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រចាំ ឲ្យគេថាគ្រីស្តបរិស័ទពូកែណាស់ដើម្បីប្រកាសដំណឹងល្អ យកចិត្តទុកដាក់សកម្មណាស់ដើម្បីចែករំលែកទ្រព្យសម្បត្តិដែលគេមានដល់បងប្អូនឯទៀតៗ។ អាម៉ែន៕